# ប្រព័ន្ធប្រាក់ឧបត្ថម្ភសម្រាប់ការសិក្សានៅសាលាកម្រិតទុតិយភូមិ

ជាប្រព័ន្ធមួយដែលរដ្ឋជួយក្នុងការបង់ថ្លៃសិក្សានៅវិទ្យាល័យជាដើម។

វិទ្យាល័យរដ្ឋ : រដ្ឋជួយបង់ថ្លៃសិក្សាត្រឹម 118,800 យ៉េនក្នុង ១ឆ្នាំ
→ថ្លៃសិក្សាដែលត្រូវបង់ គឺ 0 យ៉េន។

វិទ្យាល័យឯកជន : រដ្ឋជួយបង់ថ្លៃសិក្សាចាប់ពី 118,800 យ៉េន ដល់ 396,000 យ៉េនក្នុង ១ឆ្នាំ
→ថ្លៃសិក្សា អាចនឹងត្រូវបង់បន្តិចបន្តួច (តម្លៃត្រូវបង់ ប្រែប្រួលទៅតាមចំណូលរបស់អាណាព្យាបាល)

រដ្ឋ នឹងបង់ថ្លៃសិក្សាទៅសាលាផ្ទាល់។
សិស្ស ឬ គ្រួសារ មិនទទួលបានប្រាក់នោះទេ។

នៅពេលចូលសិក្សា សាលានឹងធ្វើការណែនាំអំពីប្រព័ន្ធនេះ។
អ្នកដែលចង់ប្រើប្រាស់ប្រព័ន្ធ សូមដាក់ពាក្យសុំទៅសាលា។
អ្នកដែលមិនបានដាក់ពាក្យសុំ នឹងត្រូវបង់ថ្លៃសិក្សាដោយខ្លួនឯង។

**អ្នកដែលអាចប្រើប្រាស់ប្រព័ន្ធនេះបាន**
ជាអ្នកដែលមានអាសយដ្ឋាននៅក្នុងប្រទេសជប៉ុន ហើយកំពុងសិក្សានៅវិទ្យាល័យជាដើម។

**សាលាដែលអាចប្រើប្រាស់បាន**

- សាលាកម្រិតទុតិយភូមិ (ខូតូ ហ្កាកកូ) (ប្រព័ន្ធពេញថ្ងៃ(ហ្សេនជីសឺ សេ) ប្រព័ន្ធពេលវេលាដាក់លាក់(ទេជី សេ) ប្រព័ន្ធសិក្សានៅផ្ទះ(ស៊ីស៊ីន សេ))
  ※ លើកលែង ផ្នែកជំនាញ (សេនកូ កា) និងផ្នែកផ្សេងៗ (បេក កា)
- សាលាកម្រិតបឋមភូមិ កម្រិត២ (ឈីតូ ខ្យូអ៊ិគី ហ្កាកកូ)
  ※ លើកលែង ផ្នែកជំនាញ (សេនកូកា) និងផ្នែកផ្សេងៗ (បេកកា)
- សាលាឧបត្ថម្ភពិសេស កម្រិតទុតិយភូមិ (តុគីបេសឺ ស៊ិអេន ហ្កាកកូ ខូតូ ប៊ឺ)
- សាលាជំនាញកម្រិតខ្ពស់ (ខូតូ សេនមុន ហ្កាកកូ) (ពីឆ្នាំទី១ ដល់ឆ្នាំទី៣)
- សាលាឯកទេស (សេនស្យឺ ហ្កាកកូ) (កម្រិតទុតិយភូមិ និង កម្រិតទូទៅ) និងសាលាគ្រប់ប្រភេទ

សាលាជនបរទេស ក៏អាចប្រើប្រាស់បានដែរ។
សម្រាប់តែសាលាដែលមានឈ្មោះនៅក្នុងគេហទំព័រខាងក្រោមប៉ុណ្ណោះ។
https://www.mext.go.jp/a_menu/shotou/mushouka/1307345.htm

ប៉ុន្តែ អ្នកដែលមានចំណុចខាងក្រោមតែមួយក៏ដោយ ក៏មិនអាចប្រើប្រាស់ប្រព័ន្ធនេះបានដែរ។

- អ្នកដែលមានអាណាព្យាបាលមានចំណូលប្រហែល 910 ម៉ឺនយ៉េន ក្នុង១ឆ្នាំ
- អ្នកដែលបានបញ្ចប់ការសិក្សាកម្រិតទុតិយភូមិ (ចប់ថ្នាក់ទី១២)
- អ្នកដែលបានសិក្សានៅវិទ្យាល័យលើសពី 36 ខែ

**ឯកសារចាំបាច់ សម្រាប់ការដាក់ពាក្យសុំ**
សូមដាក់ឯកសារខាងក្រោមទៅសាលាដែលកំពុងសិក្សា។

- ពាក្យសុំទទួលស្គាល់លក្ខណសម្បត្តិទទួលការឧបត្ថម្ភ (ជីខ្យឺ ស៊ិកាគឺ នីនទេ ស៊ីនសេស្យ)
  (ទទួលបានពីសាលា។ សូមបំពេញចំណុចចាំបាច់)
- ឯកសារចម្លងកាតផ្ទាល់ខ្លួន (ម៉ាយ ណាមបឺ កាត) ឬ ឯកសារចម្លងកាតប្រជាជន (យ៉ឺមីន ហ្សូ)
  ដែលមានសរសេរអំពីលេខកាតផ្ទាល់ខ្លួន (ម៉ាយ ណាមបឺ កាត)

新型コロナウイルス感染下における
外国にルーツがある人々への支援活動応援助成
三菱財団 × 中央共同募金会
原稿作成・翻訳：NPO法人 多言語センターFACIL
https://tcc117.jp/facil/
FACIL

អាចតម្រូវឲ្យដាក់ឯកសារស្ដីពីពន្ធ(ឯកសារបញ្ជាក់ពីការបង់ពន្ធ) ជំនួសឲ្យឯកសារចម្លងកាតផ្ទាល់ខ្លួន (ម៉ាយណាមបឺ កាត) ក៏មាន
ខុសគ្នាទៅតាមសាលានីមួយៗតាមខេត្តក្រុង។
សូមស្ដាប់ការណែនាំរបស់សាលាឲ្យបានច្បាស់លាស់។

អ្នកដែលអាចប្រើប្រាស់ប្រព័ន្ធនេះបាន មានតែអ្នកដែលបានធ្វើបែបបទបង់ពន្ធ (ពន្ធប្រជាជនតំបន់ (ឈិហូ យីមីន ហ្សេ)ប៉ុណ្ណោះ
មុនពេលដាក់ពាក្យសុំ សូមទៅធ្វើបែបបទ (ប្រកាសពន្ធប្រជាជនតំបន់) ជាដាច់ខាត។

ប្រសិនបើមានចម្ងល់ផ្សេងៗ សូមសាកសួរទៅកាន់ការិយាល័យនៅវិទ្យាល័យ។

អាចអានការពន្យល់លម្អិតអំពីប្រព័ន្ធនេះ នៅក្នុងគេហទំព័ររបស់ក្រសួងអប់រំក៏បាន។
(មានតែភាសាជប៉ុនប៉ុណ្ណោះ)
https://www.mext.go.jp/a_menu/shotou/mushouka/index.htm

ឯកសារយោង
「高校生等への就学支援」（文部科学省）
https://www.mext.go.jp/a_menu/shotou/mushouka/1342674.htm

「高校で勉強したい外国人のみなさんへ～高等学校等就学支援金制度のことを教えます～」（文部科学省・出入国在留管理庁）
http://www.moj.go.jp/isa/support/portal/guidebook_education.html

新型コロナウイルス感染下における
外国にルーツがある人々への支援活動応援助成
三菱財団 × 中央共同募金会

原稿作成・翻訳：NPO 法人 多言語センターFACIL
https://tcc117.jp/facil/
FACIL